# បុព្វកថាសេចក្ដីណែនាំសម្រាប់កុមារ និង យុវវ័យ

## នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



បុព្វកថាណែនាំសម្រាប់
**ឪពុកម្ដាយ និងថ្នាក់ដឹកនាំ**

បងប្អូនប្រុសស្រីជាទីស្រឡាញ់ ៖ កុមារ និងយុវវ័យនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាបុត្រាបុត្រីសំណព្វរបស់ព្រះ ។ ពួកគេមានសក្ដានុពលក្នុងការជះឥទ្ធិពលដ៏អស្ចារ្យលើពិភពលោកនេះ ។

គោលការណ៍ដែលបានបង្រៀននៅក្នុងកិច្ចខំប្រឹងប្រែងសម្រាប់កុមារ និងយុវវ័យនេះតំណាងឲ្យរបៀបដែលកាន់តែខ្ពង់ខ្ពស់ និងកាន់តែបរិសុទ្ធ ដើម្បីលើកទឹកចិត្តឲ្យជំនាន់កំពុងពេញវ័យធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងអនុវត្តដំណឹងល្អរបស់ទ្រង់នៅគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ ។ កិច្ចខិតខំដ៏ធំនេះនឹងដាក់បញ្ចូលការរៀនសូត្រដំណឹងល្អ ឯកសិទ្ធិក្នុងការបម្រើ ការអភិវឌ្ឍផ្ទាល់ខ្លួន និងសកម្មភាពដ៏រីករាយជាច្រើន ។ កិច្ចខិតខំនេះចាប់ផ្ដើមនៅក្នុងគេហដ្ឋាន ។ ឪពុកម្ដាយមានកាតព្វកិច្ចដ៏ពិសិដ្ឋ ដើម្បីបង្រៀនកូនចៅរបស់ពួកគេនៅក្នុងពន្លឺ និងសេចក្ដីពិត ។ ថ្នាក់ដឹកនាំទាំងឡាយរបស់សាសនាចក្រផ្ដល់ការគាំទ្រ និងការណែនាំដ៏មានតម្លៃដល់កុមារ យុវវ័យ និងក្រុមគ្រួសាររបស់ពួកគេ ។

យើងស្រឡាញ់បងប្អូន ។ យើងមានទំនុកចិត្តលើបងប្អូន ។ យើងសូមសន្យាថា ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌នឹងបន្តប្រទានពរ និងគាំទ្របងប្អូន កាលបងប្អូនដឹកនាំ និងណែនាំកូនចៅរបស់ទ្រង់ដោយសេចក្ដីជំនឿ ។

គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់

បោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍
© ២០១៩ by Intellectual Reserve, Inc.
All rights reserved.
កំណែថ្មី ៖ ៤/១៩ ។
ការបកប្រែនៃ *Introductory Guide for Parents and Leaders*
Cambodian
16855 258



## ទស្សនវិស័យ

ដើម្បីពង្រឹងសេចក្ដីជំនឿរបស់ជំនាន់កំពុងពេញវ័យលើព្រះយេស៊ូវគ្រីស្ទ ហើយជួយកុមារ យុវវ័យ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេឲ្យរីកចម្រើននៅលើផ្លូវនៃសេចក្ដីសញ្ញា នៅពេលពួកគេជួបនឹងឧបសគ្គក្នុងជីវិត ។

# សេចក្តីផ្តើម

ដោយធ្វើការរួមគ្នា ឪពុកម្តាយ និងថ្នាក់ដឹកនាំជួយកុមារ និងយុវវ័យឲ្យប្រែចិត្តជឿកាន់តែសីុជម្រៅ ក្លាយជាសិស្សដ៏សក្តិសមរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយក្លាយជាបុរស និងស្ត្រីនៃសេចក្តីទៀងត្រង់តាមរយៈ ៖

- **ការរៀនសូត្រដំណឹងល្អ** ដែលបំផុសគំនិតដល់ការប្តេជ្ញាផ្ទាល់ខ្លួន ។
- **ការបម្រើ និងសកម្មភាពនានា** ដែលស្អាងដល់រាងកាយ និងវិញ្ញាណ ។
- **ការអភិវឌ្ឍផ្ទាល់ខ្លួន** ដែលនាំឲ្យមានការរីកចម្រើនកើនឡើង ។

គោលការណ៍ណែនាំ និងតួនាទីទូទៅដែលបានចែងនៅក្នុងសៀវភៅនេះអាចសម្របសម្រួលបាន ។ មិនមានរបៀបតែមួយត្រឹមត្រូវដើម្បីអនុវត្តវានោះទេ ។ យោបល់ និងឧទាហរណ៍មួយចំនួនមាននៅលើគេហទំព័រ ChildrenandYouth.ChurchofJesusChrist.org ។ សូមស្វែងរកការបំផុសគំនិតដើម្បីដឹងពីអ្វីដែលល្អបំផុតសម្រាប់បុគ្គលម្នាក់ៗ ( សូមមើល « កែតម្រូវ និងសម្របសម្រួល » ) ។

# ជំនាន់កំពុងពេញវ័យ

ព្យាការីបានថ្លែងថា ជំនាន់កុមារ និងយុវវ័យនេះស្ថិតក្នុងចំណោមជំនាន់ល្អបំផុតដែលព្រះអម្ចាស់បានបញ្ជូនមកកាន់ផែនដីនេះ ( សូមមើល រ័សុល អិម ណិលសុន « Hope of Israel » ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ទំព័រ ១៦ ) ។ ពួកគេមានសក្តានុភាពក្នុងការជះឥទ្ធិពលដ៏អស្ចារ្យដល់ពិភពលោកនេះ ។ ពួកគេត្រូវបានអញ្ជើញឲ្យជួយប្រមូលផ្តុំសាសន៍អ៊ីស្រាអែលនៅផ្នែកទាំងសងខាងនៃវាំងនន ។ យើងត្រូវការវិធីសាស្ត្រដ៏ខ្ពស់ និងបរិសុទ្ធជាងនេះដើម្បីថែទាំ និងធ្វើការងារបម្រើដល់ពួកគេ ។ វិធីសាស្ត្រនេះនឹងជួយកុមារ និងយុវវ័យឲ្យ ៖

- ស្គាល់អត្តសញ្ញាណ និងគោលបំណងដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ ។
- ប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទកាន់តែសីុជម្រៅ ដាក់ដំណឹងល្អរបស់ទ្រង់ក្នុងចិត្តរបស់ពួកគេ ហើយបំផុសពួកគេឲ្យជ្រើសរើសធ្វើតាមទ្រង់ ។
- បំពេញកាតព្វកិច្ចបព្វជិតភាពអើរ៉ុនទាំងឡាយ ។
- ចូលរួមជាមួយគ្នានៅក្នុងកិច្ចការនៃសេចក្តីសង្គ្រោះ ។
- អភិវឌ្ឍខ្លួនដោយមានជំនួយមកពីឪពុកម្តាយ និងថ្នាក់ដឹកនាំតាមតម្រូវការ ។
- មានភាពសក្តិសមដើម្បីចូលក្នុងព្រះវិហារបរិសុទ្ធ ហើយមានអំណរក្នុងការតស៊ូនៅលើផ្លូវនៃសេចក្តីសញ្ញា ។

នៅពេលកុមារ និងយុវវ័យទទួលបានវិវរណៈសម្រាប់ជីវិតរបស់ពួកគេ បង្កើតទំនាក់ទំនងដែលផ្តោតលើដំណឹងល្អ និងអនុវត្តសិទ្ធិជ្រើសរើសកាលពួកគេធំឡើង នោះពួកគេនឹងទទួលជោគជ័យក្នុងការសម្រេចបាននូវគោលបំណងទាំងនេះ ។



> « គោលបំណងរបស់សាសនាចក្រជាយូរមកហើយ គឺដើម្បីជួយដល់សមាជិកទាំងអស់បង្កើនសេចក្តីជំនឿរបស់ពួកគេទៅលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ [ ហើយ ] ដើម្បីជួយពួកគេនៅក្នុងការចុះ និងការរក្សាសេចក្តីសញ្ញារបស់ពួកគេជាមួយនឹងព្រះ » ។
>
> ប្រធាន រ័សុល អិម ណិលសុន « ការថ្លែងសុន្ទរកថាបើកកម្មវិធី » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៧



## ព្យាយាមធ្វើតាមព្រះអង្គសង្គ្រោះ

នៅក្នុងយុវវ័យរបស់ទ្រង់ ព្រះយេស៊ូវបានរៀនពីអត្តសញ្ញាណ និងបេសកកម្មដ៏ទេវភាពរបស់ទ្រង់ គឺដូចជាបុត្រាបុត្រីម្នាក់ៗរបស់ព្រះត្រូវធ្វើដែរ ។ ទ្រង់ « កាន់តែធំប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » ( លូកា ២:៥២ ) ។ ទ្រង់បានធំឡើងក្នុងតុល្យភាពមួយ ដូច្នេះហើយកុមារ និងយុវវ័យទាំងអស់ក៏អាចធ្វើបានដូចគ្នាដែរ ។

សូមជួយកុមារ និងយុវវ័យឲ្យទទួលយកព្រះអង្គសង្គ្រោះដាក់ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ—មិនមែនគ្រាន់តែនៅថ្ងៃឈប់សម្រាកនោះទេ ។ នៅពេលពួកគេព្យាយាមដាក់ព្រះយេស៊ូវគ្រីស្ទជាស្នូលនៃជីវិតរបស់ពួកគេ នោះទ្រង់សន្យាថានឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធឲ្យធ្វើជាអង្គលួងលោម និងដឹកនាំពួកគេ ។

វិធីល្អបំផុតនោះគឺ ការធ្វើតាមព្រះអង្គសង្គ្រោះត្រូវចាប់ផ្តើមនៅក្នុងគេហដ្ឋាន ។ ថ្នាក់ដឹកនាំទាំងឡាយរបស់សាសនាចក្រអាចផ្តល់ការគាំទ្រដ៏សំខាន់ដល់បុគ្គល និងក្រុមគ្រួសារ ។




« ព្រះយេស៊ូវក៏កាន់តែធំប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » ។

លូកា ២:៥២

# ការផ្ដោតទៅលើគេហដ្ឋាន

ឪពុកម្ដាយរៀបចំផែនការបទពិសោធន៍ និងការសន្ទនាជាគ្រួសារ ដើម្បីបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយបំពេញតាមតម្រូវការពិសេសដល់កូនម្នាក់ៗ ។ ការណ៍នេះកើតឡើង នៅពេលក្រុមគ្រួសារធ្វើការ និងលេងជាមួយគ្នាតាមរបៀបនានាដែលជួយបង្រៀនជំនាញដ៏សំខាន់ៗ ពង្រឹងអត្តចរិត និងផ្ដល់ឱកាសឲ្យរីកចម្រើនឡើង ។

### លើកទឹកចិត្តឲ្យមានការរីកចម្រើន

- សូមអធិស្ឋានសូមការណែនាំ ។ ព្រះវរបិតាសួគ៌ជ្រាបពីកូនចៅរបស់អ្នក ហើយនឹងជួយអ្នកបង្រៀនពួកគេ ។
- សូមជួយកូនចៅរបស់អ្នកឲ្យស្វែងរក និងទទួលស្គាល់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។
- បង្ហាញសេចក្ដីស្រឡាញ់ ហើយសរសើរកូនចៅរបស់អ្នកឲ្យបានញឹកញាប់ចំពោះកិច្ចខិតខំរបស់ពួកគេដើម្បីធ្វើឲ្យបានល្អ និងចំពោះគុណសម្បត្តិដូចជាព្រះគ្រីស្ទដែលអ្នកឃើញនៅក្នុងពួកគេ ។
- សូមស្វែងរកឱកាសដើម្បីបម្រើមនុស្សដទៃជាក្រុមគ្រួសារមួយ ។

### ផ្ដល់ការណែនាំ

- សូមជួយកូនចៅរបស់អ្នកឲ្យឃើញពីរបៀប ដែលពួកគេអាចអនុវត្តដំណឹងល្អនៅក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ ។
- សូមណែនាំកូនចៅរបស់អ្នក និងលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅ និងផែនការផ្ទាល់ខ្លួនគេ ។
- សូមជួយពួកគេឲ្យមានដំណោះស្រាយផ្ទាល់ខ្លួនចំពោះបញ្ហានានា ។
- សូមផ្ដល់ការគាំទ្រ ជំនួយ និងការលើកទឹកចិត្តជាដរាប ។

### និយាយជាមួយថ្នាក់ដឹកនាំ

សូមប្រាស្រ័យទាក់ទងជាមួយនឹងគ្រូបង្រៀន និងថ្នាក់ដឹកនាំដើម្បីកំណត់ពីរបៀបដែលពួកគេអាចជួយគាំទ្រដល់កូនចៅរបស់អ្នកបានល្អបំផុត ។ សូមប្រុងប្រយ័ត្នមិនត្រូវបំបាក់ទំនុកចិត្តកូនចៅរបស់អ្នកឡើយ ឬក៏ធ្វើឲ្យពួកគេខ្មាស់គេទេ ។

ស្វែងរកធនធាននៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។



« វាគឺជាពេលសម្រាប់*សាសនាចក្រផ្ដោតទៅលើគេហដ្ឋាន*ដែលបានគាំទ្រដោយអ្វីដែលធ្វើឡើងនៅក្នុងអគារសាខា វួដ និងស្តេករបស់យើង » ។

ប្រធាន រ័សុល អិម ណិលសុន « ការថ្លែងសុន្ទរកថាបើកកម្មវិធី » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៧



# ការគាំទ្រដោយសាសនាចក្រ

តួនាទីរបស់សាសនាចក្ររួមមាន ការបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ធ្វើពិធីបរិសុទ្ធ និងគាំទ្រដល់គេហដ្ឋាន ។ ថ្នាក់ដឹកនាំ និងគ្រូបង្រៀនគាំទ្រឪពុកម្ដាយតាមរយៈការបង្កើតទំនាក់ទំនងដ៏រឹងមាំ និងចេះបីបាច់ទំនាក់ទំនងជាមួយនឹងកុមារ និងយុវវ័យដែលពួកគេបម្រើ ។

## និយាយជាមួយឪពុកម្ដាយ

- សូមប្រាស្រ័យទាក់ទងក្រៅផ្លូវការជាមួយឪពុកម្ដាយ ដើម្បីដឹងពីរបៀបគាំទ្រដល់កូនចៅរបស់ពួកគេ ។ សូមចែកចាយភាពខ្លាំងដែលអ្នកកត់សម្គាល់ ។
- សូមសួរពីអ្វីដែលពួកគេសង្ឃឹមចង់ឲ្យកូនចៅរបស់ពួកគេដកពិសោធន៍ ហើយរៀនសូត្រពីកូរ៉ុមបព្វជិតភាពអើរ៉ុន ថ្នាក់យុវនារី និងតាមសកម្មភាពនានា ។

នៅពេលឪពុកម្ដាយពុំមែនជាសមាជិកសកម្មក្នុងសាសនាចក្រ ៖

- សូមពន្យល់ដល់ឪពុកម្ដាយអំពីកិច្ចខិតខំដើម្បីគាំទ្រដល់កុមារ និងយុវវ័យនេះ ហើយសួរថាតើពួកគេចង់ឲ្យកូនចៅរបស់ពួកគេចូលរួមដែរឬទេ ហើយតាមរបៀបណា ។
- សូមសួរកុមារ ឬយុវវ័យពីប្រភេទនៃការគាំទ្រដែលពួកគេចង់បាន ។
- សូមនិយាយជាមួយនឹងក្រុមប្រឹក្សាវួដអំពីរបៀបរួមបញ្ចូលឪពុកម្ដាយឲ្យបានកាន់តែច្រើនតាមដែលអាចធ្វើបាន ។

## គាំទ្រកុមារ និងយុវវ័យ

- សូមជួយកុមារ និងយុវវ័យឲ្យទទួលស្គាល់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។
- សូមសួរពីអ្វីដែលពួកគេចង់រៀនសូត្រ និងដកពិសោធន៍ពីកូរ៉ុម ថ្នាក់រៀន និងសកម្មភាពនានា ។
- សូមលើកទឹកចិត្តពួកគេឲ្យដឹកនាំក្នុងការដាក់ផែនការ និងចាត់ចែងសកម្មភាព ។
- សូមគាំទ្រដល់អ្នកកាន់បព្វជិតភាពអើរ៉ុនឲ្យបំពេញការទទួលខុសត្រូវក្នុងកូរ៉ុម ។

ស្វែងរកធនធាននៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។



# ការសិក្សាដំណឹងល្អ

### នៅគេហដ្ឋាន

ការសិក្សាព្រះគម្ពីរ និងការអធិស្ឋានផ្ទាល់ខ្លួន និងជាគ្រួសារនឹងជួយកុមារ និងយុវវ័យឲ្យទទួលអារម្មណ៍ និងទទួលស្គាល់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយរៀនស្រឡាញ់ព្រះអង្គសង្គ្រោះ ។ បុគ្គលម្នាក់ៗ និងក្រុមគ្រួសារត្រូវបានលើកទឹកចិត្តឲ្យប្រើសៀវភៅ *ចូរមកតាមខ្ញុំ—សម្រាប់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ* និងពាក្យពេចន៍របស់ព្យាការីនៅរស់ដើម្បីសិក្សាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

### នៅព្រះវិហារ

កុមារ និងយុវវ័យជួបជុំគ្នាដើម្បីរៀនអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ កុមាររៀនដំណឹងល្អតាមរយៈការណែនាំក្នុងថ្នាក់ និងពេលវេលាច្រៀងក្នុងអង្គការបឋមសិក្សា ។ យុវវ័យរៀនគោលលទ្ធិនៅក្នុងថ្នាក់ និងកូរ៉ុម ។ កុមារ និងយុវវ័យត្រូវបានអញ្ជើញឲ្យចែកចាយអ្វីដែលពួកគេរៀននៅឯគេហដ្ឋាន ហើយអនុវត្តដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេ ។

ការរៀនសូត្រដំណឹងល្អ

### ការផ្ដោតទៅលើគេហដ្ឋាន

ការអធិស្ឋាន
ការសិក្សាព្រះគម្ពីរ
រាត្រីក្រុមគ្រួសារ
ថ្ងៃឈប់សម្រាក
ពង្សប្រវត្តិ

### ការគាំទ្រដោយសាសនាចក្រ

ការណែនាំស្ដីពីថ្ងៃឈប់សម្រាកថ្នាក់សិក្ខាសាលា



ស្វែងរកធនធាននៅលើគេហទំព័រ **ComeFollowMe.ChurchofJesusChrist.org** ។




# ការបម្រើ និងសកម្មភាពនានា

### នៅគេហដ្ឋាន

ការបម្រើ និងសកម្មភាពនានាបង្កើតឲ្យមានទម្លាប់សុចរិតប្រចាំថ្ងៃ ស្ថាបនាទំនាក់ទំនងគ្រួសារ បង្រៀនជំនាញជីវិត អភិវឌ្ឍឥរិយាបថដូចជាព្រះគ្រីស្ទ និងជួយកុមារ ព្រមទាំងយុវវ័យឲ្យរីកចម្រើនឡើង ។ ការបម្រើ និងសកម្មភាពនានាក្នុងក្រុមគ្រួសារអាចផ្ដោតលើតម្រូវការបុគ្គល និងគ្រួសារ ហើយផ្ដល់ឱកាសឲ្យអនុវត្តគោលការណ៍នានានៃដំណឹងល្អនៅក្នុងបទពិសោធន៍ប្រចាំថ្ងៃ ។

### នៅព្រះវិហារ

ការបម្រើ—រួមមាន អ្នកកាន់បព្វជិតភាពអើរ៉ុនបម្រើក្នុងពិធីបរិសុទ្ធសាក្រាម៉ង់—និងសកម្មភាពជាទៀងទាត់នានាផ្ដល់ឱកាសឲ្យជួបជុំគ្នា រៀនជំនាញថ្មីៗ សម្រេចបានកិច្ចការពិបាកៗ និងបង្កើតទំនាក់ទំនងដែលផ្ដោតលើដំណឹងល្អជាមួយនឹងមិត្តភក្តិស្រករគ្នា ព្រមទាំងថ្នាក់ដឹកនាំផងដែរ ។ ឱកាសទាំងនេះជួយកុមារ និងយុវវ័យឲ្យរីកចម្រើនខាងវិញ្ញាណ ខាងសង្គម ខាងរូបកាយ និងខាងប្រាជ្ញា ហើយផ្ដល់ការបម្រើដ៏មានអត្ថន័យដល់មនុស្សដទៃ ។ JustServe ( JustServe.org ) គឺជាធនធានដ៏មានតម្លៃមួយសម្រាប់ឱកាសបម្រើដល់សហគមន៍ ។



# ការអភិវឌ្ឍផ្ទាល់ខ្លួន

### នៅគេហដ្ឋាន

កុមារ និងយុវវ័យជ្រើសរើសអ្វីដែលពួកគេអាចធ្វើបាន ដើម្បីរីកចម្រើន និងរៀនធ្វើតាមព្រះអង្គសង្គ្រោះ ។ ឪពុកម្ដាយអាចជួយពួកគេឲ្យទទួលស្គាល់ពីរបៀបដែលពួកគេកំពុងរីកចម្រើនឡើងរួចហើយ និងពីចំណុចដែលពួកគេអាចត្រូវកែលម្អ ។ សកម្មភាពទាំងអស់រួមទាំងក្នុងសាសនាចក្រ សាលារៀន មិត្តភាព កីឡា សិល្បៈ ការងារ និងចំណាប់អារម្មណ៍បុគ្គលផ្សេងទៀតអាចជួយកុមារ និងយុវវ័យឲ្យធ្វើតាមព្រះយេស៊ូវគ្រីស្ទបាន ។

### នៅព្រះវិហារ

ថ្នាក់ដឹកនាំស្រឡាញ់ និងបម្រើដល់កុមារ និងយុវវ័យម្នាក់ៗ ហើយកាន់តែដឹងពីតម្រូវការ និងចំណាប់អារម្មណ៍របស់ពួកគេ ។ តាមរយៈទំនាក់ទំនងដ៏ពេញដោយក្ដីស្រឡាញ់ ថ្នាក់ដឹកនាំអាចជះឥទ្ធិពលដ៏វិសេសវិសាល និងដ៏មានអានុភាពមួយដើម្បីគាំទ្រ និងលើកទឹកចិត្តដល់កុមារ និងយុវវ័យក្នុងការបម្រើ និងរីកចម្រើនផ្ទាល់ខ្លួនរបស់ពួកគេ ។

## ការអភិវឌ្ឍផ្ទាល់ខ្លួន

### ការផ្ដោតទៅលើគេហដ្ឋាន

គោលដៅផ្ទាល់ខ្លួន
គោលដៅគ្រួសារ
ការណែនាំ
ការលើកទឹកចិត្ត
សេចក្ដីស្រឡាញ់

### ការគាំទ្រដោយសាសនាចក្រ

ការណែនាំ
ការលើកទឹកចិត្ត
យោបល់សម្រាប់គោលដៅ
ធនធានវីដេអូ

សូមស្វែងរកធនធាននានាសម្រាប់សកម្មភាព និងគោលដៅនៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។

សកម្មភាពលើសពីមួយថ្ងៃសម្រាប់យុវវ័យរួមមាន សន្និសីទដើម្បីកម្លាំងនៃយុវជន ( ដ.ក.យ ) សន្និសីទយុវវ័យ ការបោះជំរំ និងការប្រជុំគ្នាផ្សេងៗទៀត ។ សកម្មភាពទាំងនេះអាចជួយយុវវ័យឲ្យពង្រីកបំណងប្រាថ្នារបស់ពួកគេក្នុងការធ្វើតាមព្រះអង្គសង្គ្រោះ ទាញពួកគេចេញពីទម្លាប់ជាប្រចាំរបស់ពួកគេ ហើយជួយពួកគេឲ្យឃើញថាពួកគេគឺជាផ្នែកនៃក្រុមយុវវ័យដ៏ធំមួយ ដែលមានគោលដៅសុចរិតដូចគ្នា ។

## ការបម្រើ និង សកម្មភាពនានា

### ការផ្ដោតទៅលើគេហដ្ឋាន

រាត្រីក្រុមគ្រួសារ
ការបម្រើក្នុងគ្រួសារ
សកម្មភាពក្នុងគ្រួសារ
ការងារបម្រើ

### ការគាំទ្រដោយសាសនាចក្រ

ពិធីបរិសុទ្ធសាក្រាម៉ង់
យោបល់សម្រាប់ការបម្រើ និង សកម្មភាពនានា
JustServe
សកម្មភាពច្រើនថ្ងៃ
ការចាត់តាំងការងារបម្រើ



## កែតម្រូវ និងសម្រួបសម្រួល

បុគ្គលម្នាក់ៗ ក្រុមគ្រួសារនីមួយៗ និងក្រុមជំនុំនីមួយៗមានលក្ខណៈពិសេស ។ អ្វីដែលល្អបំផុតសម្រាប់អ្នកណាម្នាក់ អាចមិនល្អសម្រាប់អ្នកផ្សេងឡើយ ។ សូមធ្វើអ្វីដែលល្អសម្រាប់គ្រួសារ ថ្នាក់ កូរ៉ុម ឬវួដរបស់អ្នក ។ សូមនិយាយអំពីឱកាស និងកង្វល់របស់អ្នក ហើយស្វែងរកវិវរណៈដើម្បីដឹងពីរបៀបសម្រួលគំនិតផ្តួចផ្តើមនេះ ដើម្បីជួយដល់កុមារ និងយុវវ័យម្នាក់ៗឲ្យឈានដល់សក្តានុពលដ៏ទេវភាពរបស់ពួកគេ ។

ឧទាហរណ៍ កុមារ និងយុវវ័យនឹងមានភាពខុសគ្នាក្នុងរបៀបដែលពួកគេទទួលបានការរីកចម្រើនផ្ទាល់ខ្លួន ៖ ប្រភេទ ចំនួន និងភាពញឹកញាប់នៃគោលដៅ ក៏ដូចជាការគាំទ្រដែលពួកគេត្រូវការ គួរតែសម្រេចតាមបុគ្គលម្នាក់ៗ ។ ថ្នាក់ និងកូរ៉ុមក៏ត្រូវសម្របតាមដើម្បីបំពេញតាមតម្រូវការ ។ លើសពីនេះ ប្រភេទ និងភាពញឹកញាប់នៃសកម្មភាពអាចខុសៗគ្នាស្របតាមកាលៈទេសៈក្នុងតំបន់ ។



ស្វែងរកវិវរណៈ
បំពេញតាមតម្រូវការបុគ្គល
ធ្វើអ្វីដែលដំណើរការល្អ
ធ្វើឲ្យសាមញ្ញ

### *សូមធ្វើឲ្យសាមញ្ញ ។ ធ្វើអ្វីដែលដំណើរការល្អ ។*

ស្វែងរកធនធាននៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។



« សារលិខិតនៃដំណឹងល្អដែលស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទគឺថា យើងអាច ហើយត្រូវតែរំពឹងចង់ក្លាយជាមនុស្សកាន់តែប្រសើរដរាបណាយើងនៅរស់ » ។

ប្រធាន ហិនរី ប៊ី អាវរិង « Our Perfect Example » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៧០



« យើងរកឃើញសេចក្ដីពិត និង
អំណរស្ថិតស្ថេរតាមរយៈការមក
ស្គាល់ និងការធ្វើតាមសេចក្ដីពិតអំពី
អត្តសញ្ញាណរបស់យើង » ។

ប្រធាន ដាល្លិន អេក អូក « សេចក្ដីពិត និងផែនការ »
*Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ២៥

ស្វែងរកធនធាននៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។

# ការជម្រុញទឹកចិត្ត និងការទទួលស្គាល់

## ការជម្រុញទឹកចិត្ត

កុមារ និងយុវវ័យនឹងត្រូវបានជម្រុញទឹកចិត្តដោយធម្មជាតិ នៅពេលពួកគេមានអារម្មណ៍ពីក្ដីស្រឡាញ់ រីកចម្រើន អភិវឌ្ឍ និងទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេ ។ នៅពេលការផ្លាស់ប្ដូរ និងការរីកចម្រើនទៅជាពិបាកសម្រាប់ពួកគេ នោះសូមលើកទឹកចិត្តពួកគេឲ្យរកមើលវិធីនានាដើម្បីយកឈ្នះលើឧបសគ្គ ឬសម្របផែនការរបស់ពួកគេ ។ ទំនាក់ទំនងដ៏រឹងមាំ និងមានទំនុកចិត្តជាមួយឪពុកម្ដាយ ថ្នាក់ដឹកនាំ និងមិត្តស្រករគ្នាអាចផ្ដល់កម្លាំងឲ្យពួកគេរក្សាការព្យាយាម ។

## ការទទួលស្គាល់

នៅពេលកុមារ និងយុវវ័យរីកចម្រើន សូមសរសើរដល់កិច្ចខិតខំរបស់ពួកគេ ហើយលើកទឹកចិត្តពួកគេ ។ សូមផ្ដល់ឱកាសឲ្យពួកគេចែកចាយអ្វីដែលពួកគេកំពុងរៀន និងអបអរការរីកចម្រើនរបស់ពួកគេ ។ បន្ថែមលើនេះ កុមារ និងយុវវ័យទាំងអស់អាចទទួលបានវត្ថុដូចជា ចិញ្ចៀន ឬមេដាយមួយដើម្បីរំឭកពួកគេថា ពួកគេគឺជាផ្នែកនៃក្រុមទូទាំងពិភពលោកមួយដែលខិតខំដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ នៅពេលកុមារ និងយុវវ័យធ្វើតាមគោលដៅខាងវិញ្ញាណ ខាងសង្គម ខាងរូបកាយ និងប្រាជ្ញាទាំងឡាយ នោះពួកគេអាចទទួលបានបន្ទោងបន្ថែមទៀត ។



ស្ដាប់
សរសើរដល់កិច្ចខិតខំ
អបអរនឹងការរីកចម្រើន
រៀនពីកំហុស

# គេហដ្ឋាន និងឪពុកម្ដាយ

### តើតួនាទីរបស់ខ្ញុំគឺជាអ្វី ?

សូមធ្វើជាគំរូដ៏សុចរិតដល់កូនចៅរបស់អ្នក ។ បង្រៀនពួកគេពីរបៀបរីកចម្រើនឡើងក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ ។ ស្វែងរករបៀបដើម្បីជួយពួកគេឲ្យរៀនពីក្ដីអំណរក្នុងការកាន់តាមសេចក្ដីសញ្ញា ការស្វែងរកទេពកោសល្យថ្មីៗ និងការធ្វើរឿងដែលពិបាកៗ ។ ជួយគ្រួសាររបស់អ្នកឲ្យកាន់តែខិតទៅជិតព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅតាមដំណឹងល្អក្នុងជីវិតប្រចាំថ្ងៃ ។

### តើខ្ញុំត្រូវធ្វើអ្វី ?

សូមឲ្យកូនៗរបស់អ្នកដឹងថា អ្នកស្រឡាញ់ពួកគេខ្លាំងប៉ុណ្ណា ។ ចូលរួមក្នុងជីវិតរបស់ពួកគេ ។ អធិស្ឋានរកមើលតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ ហើយដាក់ផែនការសិក្សាដំណឹងល្អ និងសកម្មភាពនានាដើម្បីដោះស្រាយតម្រូវការទាំងនោះ ។ ចែកចាយទីបន្ទាល់របស់អ្នកជាមួយពួកគេឲ្យបានទៀងទាត់ ។ និយាយជាមួយថ្នាក់ដឹកនាំអំពីរបៀបដែលពួកគេអាចជួយគាំទ្រដល់កូនចៅរបស់អ្នក ។

### តើខ្ញុំត្រូវចាប់ផ្ដើមនៅត្រង់ណា ?

សូមបន្តនិយាយ និងស្ដាប់កូនចៅរបស់អ្នក ។ អធិស្ឋានអំពីរបៀបដែលអ្នកអាចគាំទ្រដល់ពួកគេ ។ ជួយពួកគេឲ្យស្វែងរក និងចាប់ផ្ដើមពង្រឹងផ្នែកនៃការរៀនសូត្រ ដែលពួកគេចាប់អារម្មណ៍ ។ ចាប់ផ្ដើម ឬបន្តការអធិស្ឋានជាគ្រួសារ ការសិក្សាដំណឹងល្អ ឱកាសបម្រើ និងសកម្មភាពនានាដើម្បីជួយកូនចៅរបស់អ្នកឲ្យរីកចម្រើនឡើង ។



បង្ហាញសេចក្ដីស្រឡាញ់
ធ្វើជាគំរូ
ស្វែងរកវិវរណៈ
បង្រៀនជំនាញជីវិត
អបអរនឹងការរីកចម្រើន
សរសើរដល់កិច្ចខិតខំ

ស្វែងរកធនធាននៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។



« គ្មានកិច្ចការណាទៀត ដែលប្រពៃជាងការធ្វើជាឪពុកម្ដាយដ៏សុចរិត និងដែលចេះគិតគូនោះទេ ! »

ប្រធាន រ័សុល អិម ណិលសុន
« ថ្ងៃឈប់សម្រាកជាថ្ងៃមួយដ៏សប្បាយ »
*Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៣១



« ទ្រព្យសម្បត្តិធំបំផុតលើផែនដី និងស្ថានសួគ៌គឺកូនចៅ និងពូជពង្សយើង » ។

ប្រធាន ដាល្លិន អេក អូក « The Great Plan of Happiness » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៧៥

ស្វែងរកធនធាននៅលើគេហទំព័រ **Primary.ChurchofJesusChrist.org** ។

# ថ្នាក់ដឹកនាំ និងគ្រូបង្រៀនអង្គការបឋមសិក្សា

## តើតួនាទីរបស់ខ្ញុំគឺជាអ្វី ?

ចូរស្រឡាញ់ និងពង្រឹងកូនចៅ ។ សូមជួយឪពុកម្ដាយក្នុងការជួយកូនចៅឲ្យមានអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌សម្រាប់ពួកគេ យល់ពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ទទួលអារម្មណ៍ និងទទួលស្គាល់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយរៀបចំចុះ និងរក្សាសេចក្ដីសញ្ញាដ៏ពិសិដ្ឋ ។

## តើខ្ញុំត្រូវធ្វើអ្វី ?

សូមធានាថា ថ្នាក់អង្គការបឋមសិក្សា និងពេលវេលាច្រៀងជួយកុមារឲ្យមានអារម្មណ៍អំពីព្រះវិញ្ញាណ បង្កើនសេចក្ដីជំនឿ និងមានអំណរចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរបស់ពួកគេ ។ ដោយមានផ្នែកនៃការរីកចម្រើនដែលបានស្នើនៅក្នុង លូកា ២:៥២ ទុកជាសេចក្ដីណែនាំ សូមគ្រោងសកម្មភាពរីករាយ និងការបម្រើ ក៏ដូចជាសកម្មភាពទាក់ទាញនានា ដែលស្ថាបនាទីបន្ទាល់ ពង្រឹងដល់ក្រុមគ្រួសារ ព្រមទាំងចិញ្ចឹមបីបាច់សាមគ្គីភាព និងការរីកចម្រើនផ្ទាល់ខ្លួន ។

## តើខ្ញុំត្រូវចាប់ផ្ដើមនៅត្រង់ណា ?

សូមស្គាល់កូនចៅ និងក្រុមគ្រួសាររបស់ពួកគេ ហើយបម្រើតាមតម្រូវការរបស់ពួកគេ ។ ក្នុងនាមជាគណៈប្រធានថ្នាក់អង្គការបឋមសិក្សា សូមអធិស្ឋានសួរពីរបៀបដែលអ្នកអាចជួយគ្រូបង្រៀនរបស់អ្នក អ្នកដឹកនាំតន្ត្រី និងអ្នកដឹកនាំសកម្មភាព ដើម្បីជួយកុមារឲ្យធ្វើតាមព្រះអង្គសង្គ្រោះ ។



បង្រៀនពីអត្តសញ្ញាណជាព្រះ
អនុវត្តដំណឹងល្អ
បង្កើតទំនាក់ទំនង
បង្រៀនសេចក្ដីសញ្ញា
បង្រៀនជំនាញជីវិត

# ថ្នាក់ដឹកនាំក្រុមយុវនារី

## តើតួនាទីរបស់ខ្ញុំគឺជាអ្វី ?

សូមជួយឪពុកម្ដាយ និងគណៈប៊ីស្សព ក្នុងការណែនាំ និងបំផុសគំនិតដល់យុវនារីឲ្យយល់ពីអត្តសញ្ញាណរបស់ពួកគេជាបុត្រីរបស់ព្រះ រៀបចំសម្រាប់សេចក្ដីសញ្ញាក្នុងព្រះវិហារបរិសុទ្ធ និងបំពេញតាមគោលបំណងដ៏ទេវភាពរបស់ពួកគេ ។ ណែនាំដល់គណៈប្រធានថ្នាក់ នៅពេលពួកគេដឹកនាំ ផ្ដល់ការងារបម្រើ និងបម្រើដល់សមាជិកក្នុងថ្នាក់របស់ពួកគេ ។

## តើខ្ញុំត្រូវធ្វើអ្វី ?

សូមធ្វើជាគំរូមួយក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ ណែនាំគណៈប្រធានថ្នាក់ នៅពេលពួកគេដាក់គម្រោងប្រកបដោយការអធិស្ឋាន និងជួយបង្រៀនមេរៀនមកពី *ចូរមកតាមខ្ញុំ—សម្រាប់យុវនារី* ។ លើកទឹកចិត្តពួកគេឲ្យដឹកនាំតាមការគ្រោង និងធ្វើការបម្រើ និងសកម្មភាពនានាដែលនឹងជួយយុវនារីឲ្យរីកចម្រើនក្នុងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេ ។ ផ្ដល់ការគាំទ្របន្ថែមដល់យុវនារីដែលត្រូវការវា ។

## តើខ្ញុំត្រូវចាប់ផ្ដើមនៅត្រង់ណា ?

សូមរៀនស្គាល់យុវនារីម្នាក់ៗ ។ និយាយជាមួយយុវនារី ឪពុកម្ដាយរបស់ពួកគេ និងគណៈប៊ីស្សពអំពីរបៀបដែលអ្នកអាចគាំទ្រដល់ការរីកចម្រើនរបស់យុវនារី ។ អធិស្ឋានដើម្បីដឹងរបៀបដែលអ្នកអាចជួយគណៈប្រធានថ្នាក់របស់អ្នកឲ្យជោគជ័យក្នុងការហៅបម្រើរបស់ពួកគេ ។



បង្រៀនពីអត្តសញ្ញាណជាព្រះ
បំពេញកិច្ចការនៃសេចក្ដីសង្គ្រោះ
រៀបចំសម្រាប់តួនាទីដ៏ទេវភាព
អភិវឌ្ឍភាពក្លៀវក្លា
បង្រៀនជំនាញជីវិត

ស្វែងរកធនធាននៅលើគេហទំព័រ **YoungWomen.ChurchofJesusChrist.org** ។





សូមនៅជាមួយពួកគេ ។
ភ្ជាប់ពួកគេទៅស្ថានសួគ៌ ។
ឲ្យពួកគេដឹកនាំ ។

ស្វែងរកធនធាននៅលើគេហទំព័រ **YoungMen.ChurchofJesusChrist.org** ។

# ថ្នាក់ដឹកនាំបព្វជិតភាពអើរ៉ុន

### តើតួនាទីរបស់ខ្ញុំគឺជាអ្វី ?

សូមជួយឪពុកម្ដាយ និងគណៈប៊ីស្សពក្នុងការរៀបចំយុវជនសម្រាប់ការតែងតាំងទៅតំណែងបព្វជិតភាព សេចក្ដីសញ្ញាក្នុងព្រះវិហារបរិសុទ្ធ បេសកកម្ម និងតួនាទីដ៏ទេវភាព ។ បំផុសគំនិតពួកគេឲ្យយល់ពីគោលបំណង និងអត្តសញ្ញាណរបស់ពួកគេក្នុងនាមជាបុត្រារបស់ព្រះ ។ ណែនាំដល់គណៈប្រធានកូរ៉ុម នៅពេលពួកគេដឹកនាំ ផ្ដល់ការងារបម្រើ និងបម្រើដល់សមាជិកក្នុងកូរ៉ុមរបស់ពួកគេ និងនៅពេលពួកគេបម្រើក្នុងពិធីបរិសុទ្ធសាក្រាម៉ង់ ។

### តើខ្ញុំត្រូវធ្វើអ្វី ?

សូមធ្វើជាគំរូមួយក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ ណែនាំគណៈប្រធានកូរ៉ុម នៅពេលពួកគេអនុវត្តកូនសោរបស់គេ បម្រើក្នុងពិធីបរិសុទ្ធសាក្រាម៉ង់ និងដាក់គម្រោងប្រកបដោយការអធិស្ឋាន ព្រមទាំងជួយបង្រៀនមេរៀនមកពី *ចូរមកតាមខ្ញុំ—សម្រាប់យុវជន* ។ ជួយពួកគេឲ្យដាក់គម្រោង និងធ្វើការបម្រើ និងសកម្មភាពនានាដែលនឹងជួយយុវជនឲ្យរីកចម្រើនក្នុងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេ ។ ឲ្យពួកគេដឹកនាំ ។ ផ្ដល់ការគាំទ្របន្ថែមដល់យុវជនដែលត្រូវការវា ។

### តើខ្ញុំត្រូវចាប់ផ្ដើមនៅត្រង់ណា ?

សូមចំណាយពេលជាមួយយុវជន ។ រៀនស្គាល់ និងស្រឡាញ់ពួកគេម្នាក់ៗ ។ និយាយជាមួយគណៈប៊ីស្សព យុវជន និងឪពុកម្ដាយរបស់ពួកគេ ដើម្បីកំណត់ពីរបៀបដែលអ្នកអាចគាំទ្រពួកគេ កាលពួកគេរីកចម្រើន ហើយក្លាយដូចជាព្រះអង្គសង្គ្រោះ ។ អធិស្ឋានដើម្បីដឹងរបៀបដែលអ្នកអាចជួយគណៈប្រធានកូរ៉ុមរបស់អ្នកឲ្យអនុវត្តកូនសោរបស់ពួកគេ និងទទួលបានជោគជ័យក្នុងការហៅបម្រើរបស់ពួកគេ ។



បង្រៀនកាតព្វកិច្ចបព្វជិតភាព
បំពេញកិច្ចការនៃសេចក្ដីសង្គ្រោះ
រៀបចំសម្រាប់តួនាទីដ៏ទេវភាព
អភិវឌ្ឍភាពក្លៀវក្លា
បង្រៀនជំនាញជីវិត

# គ្រូបង្រៀនថ្នាក់សាលាថ្ងៃអាទិត្យ

### តើតួនាទីរបស់ខ្ញុំគឺជាអ្វី ?

សូមខិតខំជួយយុវវ័យឲ្យមករកព្រះគ្រីស្ទ តាមរយៈការរៀនសូត្រ និងធ្វើតាមគោលលទ្ធិរបស់ទ្រង់ ។ បង្រៀនយុវវ័យឲ្យយល់ដឹង ចែកចាយ និងរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

### តើខ្ញុំត្រូវធ្វើអ្វី ?

សូមធ្វើជាគំរូមួយក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ហើយជួយយុវវ័យឲ្យស្ថាបនាសេចក្ដីជំនឿរបស់ពួកគេ ។ លើកទឹកចិត្តពួកគេឲ្យសិក្សាបទគម្ពីរនៅគេហដ្ឋាន—ដោយផ្ទាល់ខ្លួន និងជាមួយនឹងក្រុមគ្រួសាររបស់ពួកគេ ។ ជួយពួកគេឲ្យរៀបចំ និងបង្រៀនគោលការណ៍នានានៃគោលលទ្ធិ ។ អញ្ជើញពួកគេឲ្យអនុវត្តអ្វីដែលពួកគេកំពុងរៀនដើម្បីមានការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេ ។

### តើខ្ញុំត្រូវចាប់ផ្ដើមនៅត្រង់ណា ?

សូមព្យាយាមបង្រៀនដូចជាព្រះអង្គសង្គ្រោះបានធ្វើ ។ រៀនស្គាល់យុវវ័យម្នាក់ៗ ។ អធិស្ឋានដើម្បីដឹងរបៀបដែលអ្នកអាចជួយពួកគេឲ្យរីកចម្រើនឡើងហើយក្លាយដូចជាព្រះអង្គសង្គ្រោះកាន់តែខ្លាំង ។ ពង្រឹងសមាជិកថ្នាក់ និងឪពុកម្ដាយរបស់ពួកគេក្នុងកិច្ចខំប្រឹងដើម្បីរៀនសូត្រ និងបង្រៀនដំណឹងល្អនៅសាសនាចក្រ និងនៅឯគេហដ្ឋានរបស់ពួកគេ ។



ស្ថាបនាទីបន្ទាល់
បង្រៀនគោលលទ្ធិ
សិក្សាព្រះគម្ពីរ
បង្កើតទម្លាប់សុចរិត

ស្វែងរកធនធាននៅលើគេហទំព័រ **SundaySchool.ChurchofJesusChrist.org** ។



« ចូរស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្ដីជំនឿផង » ។

គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨



« នៅពេលយើងចុះប្រឡូកនៅក្នុងការបម្រើដល់មនុស្សដទៃ យើងមិនសូវគិតអំពីខ្លួនឯង ហើយព្រះវិញ្ញាណបរិសុទ្ធអាចងាយនឹងមករកយើង » ។

ប្រធាន ហិនរី ប៊ី អាវរិង « ការងារបម្រើដ៏បំផុសគំនិត » *Ensign* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៦៤

ស្វែងរកធនធាននៅលើគេហទំព័រ **ChildrenandYouth.ChurchofJesusChrist.org** ។

# គណៈប៊ីស្សព និងគណៈប្រធានកូរ៉ុម និងថ្នាក់

**តើតួនាទីរបស់ពួកគេគឺជាអ្វី ?**

គណៈប៊ីស្សពគឺជាគណៈប្រធាននៃបព្វជិតភាពអើរ៉ុននៅក្នុងវួដនេះ ហើយទទួលខុសត្រូវលើយុវនារី និងយុវជន ។ គណៈប្រធានកូរ៉ុមបព្វជិតភាពអើរ៉ុនធ្វើការដោយកូនសោ ដែលបានប្រគល់ដល់គេ នៅពេលប្រធានកូរ៉ុមត្រូវបានញែកចេញ ។ គណៈប្រធានថ្នាក់យុវនារីធ្វើការនៅក្រោមសិទ្ធិអំណាចបព្វជិតភាព បន្ទាប់ពីពួកគេត្រូវបានញែកចេញដោយសមាជិកម្នាក់នៃគណៈប៊ីស្សព ។

**តើពួកគេធ្វើការងារអ្វី ?**

គណៈប្រធានគួរតែខិតខំដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេជួយសមាជិកក្នុងកូរ៉ុម ឬថ្នាក់ម្នាក់ៗឲ្យមានអារម្មណ៍នៃក្ដីស្រឡាញ់ និងស្វែងរកអំណរក្នុងការរស់នៅតាមដំណឹងល្អ ។ នៅក្រោមការដឹកនាំពីគណៈប៊ីស្សព គណៈប្រធានកូរ៉ុមដឹកនាំអ្នកកាន់បព្វជិតភាពអើរ៉ុននៅពេលពួកគេបម្រើក្នុងពិធីបរិសុទ្ធសាក្រាម៉ង់ ។ ទាំងគណៈប្រធានកូរ៉ុម និងថ្នាក់ទាំងឡាយដឹកនាំការប្រមូលអ៊ីស្រាអែលដែលនៅទាំងសងខាងវាំងនន និងថែទាំដល់អ្នកដែលខ្វះខាត ។

**តើពួកគេត្រូវចាប់ផ្ដើមនៅត្រង់ណា ?**

គណៈប្រធានរៀនពីកាតព្វកិច្ចរបស់ពួកគេមកពីព្រះអម្ចាស់ និងថ្នាក់ដឹកនាំរបស់ពួកគេ ។ ពួកគេអធិស្ឋានសម្រាប់សមាជិកកូរ៉ុម ឬថ្នាក់ ហើយរៀនដឹងពីតម្រូវការរបស់ពួកគេ ។ ពួកគេគាំទ្រសមាជិកទាំងនោះឲ្យក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេប្រឹក្សារួមគ្នាអំពីមេរៀន សកម្មភាព និងការបម្រើណាមួយដែលនឹងប្រទានពរ និងពង្រឹងដល់យុវវ័យ ហើយនាំឲ្យមានសាមគ្គីភាពដល់កូរ៉ុម ឬថ្នាក់របស់ពួកគេ ។



ផ្ដល់ការងារបម្រើ
ប្រឹក្សាជាមួយគ្នា
បង្កើតសាមគ្គីភាព
បំពេញកាតព្វកិច្ច

# ធនធានជំនួយ

យើងមានធនធានចល័តតាមទូរសព្ទ គេហទំព័រ និងបោះពុម្ព ។ ឪពុកម្ដាយ ថ្នាក់ដឹកនាំជាមជ្ឈិមវ័យ កូរ៉ុម និង ប្រធានថ្នាក់ទាំងឡាយ ព្រមទាំង យុវវ័យអាចប្រើឧបករណ៍សម្រាប់ ដាក់គោលដៅ យោបល់សម្រាប់ដាក់ គោលដៅ យោបល់សម្រាប់ការបម្រើ និងសកម្មភាពនានានៅគេហដ្ឋាន និង នៅសាសនាចក្រ សេចក្ដីណែនាំស្ដីពី សុវត្ថិភាព និងការណែនាំនានាបាន ។




**កម្មវិធីទូរសព្ទ ៖ ការរស់នៅតាមដំណឹងល្អ ( Gospel Living )**

កម្មវិធីទូរសព្ទការរស់នៅតាមដំណឹងល្អ ( Gospel Living ) ( iOS និង Android ) ត្រូវបានរៀបចំឡើងដើម្បីបំផុសគំនិត ទាក់ទាញ បង្កើតភាពរីករាយ និងទាក់ទងនឹងជីវិតប្រចាំថ្ងៃ ។ វាគាំទ្រជីវិតដែលផ្ដោតលើព្រះគ្រីស្ទតាមរយៈ ៖

- មាតិកាដ៏បំផុសគំនិត
- ការរំឭក
- យោបល់សម្រាប់សកម្មភាព
- ទំនាក់ទំនង
- ការកត់កំណត់ហេតុ
- គោលដៅផ្ទាល់ខ្លួន

សូមស្វែងរកក្នុងហាងកម្មវិធី Apple និងកម្មវិធី Android នូវកម្មវិធីការរស់នៅតាមដំណឹងល្អ ( Gospel Living ) ( សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ) ។



**គេហទំព័រ ៖ ChildrenandYouth.ChurchofJesusChrist.org**

គេហទំព័រការអភិវឌ្ឍកុមារ និងយុវវ័យផ្ដល់ជាធនធាននានាដើម្បីគាំទ្រដល់ឪពុកម្ដាយ កុមារ យុវវ័យ និងថ្នាក់ដឹកនាំ ។

- ធនធានសម្រាប់ឪពុកម្ដាយ និងគ្រួសារ
- ធនធាន និងឧទាហរណ៍ស្ដីពីរបៀបគាំទ្រ និងលើកទឹកចិត្តដល់កុមារ និងយុវវ័យ
- ធនធានសកម្មភាពសម្រាប់អង្គការបឋមសិក្សា
- សេចក្ដីណែនាំ ឧទាហរណ៍ និងយោបល់សម្រាប់ការបម្រើ និងសកម្មភាពនានា
- ឧទាហរណ៍ និងយោបល់សម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួន ( គោលដៅ )
- ធនធានហ្វឹកហ្វឺនគណៈប្រធានថ្នាក់ និងកូរ៉ុម
- កំណែសម្ភារបោះពុម្ពដែលអាចទាញយកបាន



**បោះពុម្ព ៖ ការអភិវឌ្ឍកុមារ និងយុវវ័យ**

ពេលណាមានប្រយោជន៍ សៀវភៅបោះពុម្ពមានដើម្បីប្រើគាំទ្រដល់គោលការណ៍នៃការអភិវឌ្ឍកុមារ និងយុវវ័យ និងជួយកុមារ និងយុវវ័យឲ្យដាក់ផែនការសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួន ។

# បន្តនៅលើផ្លូវនៃសេចក្ដីសញ្ញា

នៅពេលយុវវ័យឈានទៅដំណាក់កាលបន្ទាប់នៃជីវិតរបស់ពួកគេ សមាគមសង្គ្រោះ និងកូរ៉ុមអែលឌើរនឹងផ្ដល់ឱកាសច្រើនឡើងឲ្យពួកគេរកឃើញអំណរ និងការរីកចម្រើន នៅពេលពួកគេធ្វើការរួមគ្នាដើម្បីសម្រេចកិច្ចការនៃសេចក្ដីសង្គ្រោះ ។

« *រាល់ពេល*ដែលប្អូនៗធ្វើ*អ្វីមួយ*ដើម្បីជួយ*នរណាម្នាក់*—ទាំងសងខាងនៃវាំងនន—បោះជំហានទៅធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះ. . . នោះប្អូនៗកំពុងជួយប្រមូលអ៊ីស្រាអែលហើយ » ។

ប្រធាន រ័សុល អិម ណិលសុន « សង្ឃឹមអ៊ីស្រាអែល » ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យ ថ្ងៃទី ខែ មិថុនា ឆ្នាំ ២០១៨ ទំព័រ ១៥

## កូរ៉ុមអែលឌើរ



## សមាគមសង្គ្រោះ





ដោយធ្វើការរួមគ្នា ឪពុកម្ដាយ និងថ្នាក់ដឹកនាំ
ជួយកុមារ និងយុវវ័យឲ្យប្រែចិត្តជឿកាន់តែ
ស៊ីជម្រៅ ក្លាយជាសិស្សដ៏សក្ដិសមរបស់
ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយក្លាយជា
បុរស និងស្ត្រីនៃសេចក្ដីទៀងត្រង់ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០១៩ by Intellectual Reserve, Inc. All rights reserved. Printed in the USA. កំណែថ្មី ៖ ៤/១៩ ។. ការបកប្រែនៃ *Introductory Guide for Parents and Leaders.*
Cambodian.16855 258

CAMBODIAN
4 02168 55258 0
16855 258